ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ:..........................................

ថ្ងៃច័ន្ទ ៣ កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០២២

# សេចក្តីជូនដំណឹងដល់សាធារណៈជន

## ស្តីពី ការដាក់ដេញថ្លៃជាសាធារណៈ ជ្រើសរើសអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានកិត្តិយសជម្រាបជូនសាធារណៈជន ទាំងអស់ ឱ្យបានជ្រាបថា៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានសហការជាមួយកម្មវិធីការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) ដែលទទួលជំនួយឥតសំណងពីក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) នៃរដ្ឋាភិបាលអូស្ត្រាលី ក្នុងគោលបំណងធ្វើការសិក្សាផ្គត់ផ្គង់ទឹកស្អាតតាមទុយោ នៅឃុំជលសារ និងឃុំកំពង់អុស ក្នុងស្រុកជលគីរី និងឃុំសំរោងសែន ក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។

ក្រសួងសូមប្រកាសជូនដំណឹងដាក់ដេញថ្លៃជាសាធារណៈ ជ្រើសរើសអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតសម្រាប់ភូមិទាំងអស់ នៅក្នុងឃុំទាំងបីខាងលើ ដែលមានលក្ខខណ្ឌ ដូចខាងក្រោមនេះ ៖

១- ទុនវិនិយោគសរុប៖ **២៧៧ ៣៧៦ ដុល្លារអាមេរិក** សម្រាប់អនុវត្តគម្រោងរយៈពេល **៥ឆ្នាំ**

២- អ្នកចូលរួមត្រូវមាន៖ ទុនវិនិយោគយ៉ាងតិច **៣៥% (៩៧ ០៨១ ដុល្លាអាមេរិច) នៃទុនវិនិយោគសរុប**

៣- ប្រាក់កក់ធានាចូលរួមដេញថ្លៃ៖ **៥ 000 ដុល្លារអាមេរិក** (មានលិខិតបញ្ជាក់ពីធនាគារ)

៤- ថវិកាឧបត្ថម្ភពីគម្រោង (3i)៖ **១១៧ ៥៣៩ ដុល្លារអាមេរិក** (ឧបត្ថម្ភតាមលទ្ធផលនៃជំហាននីមួយៗ)

៥- ថ្លៃលក់ទឹក (ដេញថ្លៃ)៖ **ចាប់ពី 0ម៣ ដល់ ៣ម៣៖ ២ ៤00 ៛/ម៣**

**ចាប់ពី ៤ម៣ ឡើងទៅ៖ ចន្លោះពី ២ ៥00 ៛/ម៣ ដល់ ២ ៦00 ៛/ម៣**

៦- ព័ត៌មានលម្អិតមានក្នុងឯកសារដេញថ្លៃ ដែលអាចរកជាវបាននៅនាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ លោកអ្នកក៏អាចស្វែងរកព័ត៌មានសង្ខេបថ្មីសំខាន់ៗ ក្នុងគេហទំព័រ៖ www.3icambodia.org

៧- កិច្ចប្រជុំណែនាំស្តីពីការរៀបចំឯកសារចូលរួមដេញថ្លៃនឹងប្រព្រឹត្តទៅនៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ០២:00 រសៀល នៅទីស្តីការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ។

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅ នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០២២ វេលាម៉ោង ០២:00 រសៀលនៅទីស្តីការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាកំហិត។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**ស៊ឹម ស៊ីថា**


**ទំនាក់ទំនង៖**

- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
  លោក សឿង យុត្តិរ៉ា
  Tell: 092 768 699
- កម្មវិធីការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i)
  Tell: 081 222 707
  អ៊ីមែល៖ info@3icambodia.org